**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៦ សជណ.កបធ

## សេចក្តីថ្លែងហេតុ

## អំពី

## សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ត្រូវបានអនុម័តដោយសន្និសីទអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩ ដូចដែលមានចែងក្នុងមាត្រាទី១៤ នៃធម្មនុញ្ញរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ។ បន្ទាប់ពីទទួលបានសេចក្តីសម្រេចភ្លាម កិច្ចព្រមព្រៀងត្រូវបើកឱ្យមានការចុះហត្ថលេខារយៈពេលមួយឆ្នាំ។ កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៦ រយៈពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់តម្កល់ឯកសារគតិយុត្តិទី២៥នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ជាមួយនឹងការតម្កល់ឯកសារនៅអគ្គនាយកនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិដែលជាអ្នកទទួលបន្ទុកតម្កល់ឯកសារនៃកិច្ចព្រមព្រៀងនេះ។ មកដល់ខែឧសភា ឆ្នាំ២០១៩នេះ មានប្រទេសចំនួន៦០ រួមទាំងសហភាពអឺរ៉ុបបានចូលរួមជាភាគីអនុវត្តកិច្ចព្រមព្រៀងនេះ ក្នុងនោះប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍មានចំនួន៥ រួមមានប្រទេស មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងប្រទេសវៀតណាម។ មកដល់បច្ចុប្បន្ន កិច្ចព្រមព្រៀងវិធានការរដ្ឋម្ចាស់កំពង់ផែ គឺជាឯកសារគតិយុត្តិដ៏សំខាន់តែមួយគត់ដែលមានគោលបំណងប្រយុទ្ធប្រឆាំងនិងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត តាមរយៈការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែឱ្យមានប្រសិទ្ធភាព និងដើម្បីធានាបាននូវការអភិរក្សយូរអង្វែង និងប្រើធនធានមានជីវិត និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឱ្យមាននិរន្តរភាព។ ម្យ៉ាងវិញទៀត កិច្ចព្រមព្រៀងនេះមានគោលបំណងទប់ស្កាត់ផលនេសាទដែលមានប្រភពពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតចូលទៅក្នុងទីផ្សារអន្តរជាតិនិងមិនលើកទឹកចិត្តឱ្យចូលរួមក្នុងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ រួមមាន១០ផ្នែកនិង៣៧មាត្រា ចែងអំពីបទប្បញ្ញត្តិសំខាន់ៗដូចខាងក្រោម៖

**ផ្នែកទី១**: បទប្បញ្ញត្តិទូទៅ មាន៦មាត្រា (មាត្រា១ដល់មាត្រា៦)

ផ្នែកនេះចែងអំពីការប្រើវាក្យស័ព្ទ គោលបំណង ការអនុវត្ត ទំនាក់ទំនងជាមួយច្បាប់និងលិខិតតូបករណ៍អន្តរជាតិដទៃទៀត សមាហរណកម្មនិងការសម្របសម្រួលថ្នាក់ជាតិ និងកិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្តូរព័ត៌មាន។

ផ្នែកទី២: ការចូលចតនៅកំពង់ផែ មាន៤មាត្រា (មាត្រា៧ដល់មាត្រា១០)

ផ្នែកនេះចែងអំពីការកំណត់កំពង់ផែ សំណើសុំមុនការចូលចតកំពង់ផែ ការអនុញ្ញាតឬការបដិសេធចូលចតនៅកំពង់ផែ និងករណីប្រធានសក្តិឬគ្រោះថ្នាក់។

ផ្នែកទី៣: ការប្រើកំពង់ផែ មាន១មាត្រា (មាត្រា១១)

ផ្នែកនេះចែងអំពីការប្រើកំពង់ផែ។

ផ្នែកទី៤: អធិការកិច្ច និងសកម្មភាពតាមដាន មាន៨មាត្រា (មាត្រា១២ដល់មាត្រា១៩)

ផ្នែកនេះចែងអំពីកម្រិតនិងអាទិភាពសម្រាប់អធិការកិច្ច ដំណើរការនៃការធ្វើអធិការកិច្ច លទ្ធផលនៃការធ្វើអធិការកិច្ច ការបញ្ជូនលទ្ធផលនៃការធ្វើអធិការកិច្ច ការផ្លាស់ប្តូរព័ត៌មានតាមអេឡិចត្រូនិច ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច វិធានការរដ្ឋម្ចាស់កំពង់ផែក្រោយការធ្វើអធិការកិច្ច និងព័ត៌មានឧបាស្រ័យនៅក្នុងរដ្ឋម្ចាស់កំពង់ផែ។

ផ្នែកទី៥: តួនាទីរដ្ឋម្ចាស់ទង់ជាតិ មាន១មាត្រា (មាត្រា២០)

ផ្នែកនេះចែងអំពីតួនាទីរដ្ឋម្ចាស់ទង់ជាតិ។

ផ្នែកទី៦: តម្រូវការរដ្ឋកំពុងអភិវឌ្ឍន៍ មាន១មាត្រា (មាត្រា២១)

ផ្នែកនេះចែងអំពីតម្រូវការកំពុងអភិវឌ្ឍន៍។

ផ្នែកទី៧: ការដោះស្រាយវិវាទ មាន១មាត្រា (មាត្រា២២)

ផ្នែកនេះចែងអំពីការដោះស្រាយវិវាទដោយសន្តិវិធី។

ផ្នែកទី៨: ភាគីមិនមែនជាសមាជិក មាន១មាត្រា (មាត្រា២៣)

ផ្នែកនេះចែងអំពីភាគីមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀង។

ផ្នែកទី៩: ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ មាន១មាត្រា (មាត្រា២៤)

ផ្នែកនេះចែងអំពីការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ។

ផ្នែកទី១០: អវសានប្បញ្ញត្តិ មាន១៣មាត្រា (មាត្រា២៥ដល់មាត្រា៣៧)

ផ្នែកនេះចែងអំពីការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ការចូលជាសមាជិក ការចូលរួមរបស់អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ការចូលជាធរមាន ការបម្រុងទុកនិងការលើកលែង សេចក្តីប្រកាសនិងសេចក្តីថ្លែងការណ៍ ការអនុវត្តបណ្តោះអាសន្ន វិសោធនកម្ម ឧបសម្ព័ន្ធ ការដកខ្លួនចេញ អ្នកតម្កល់ឯកសារ និងអត្ថបទស្របច្បាប់។

កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ទទួលស្គាល់នូវតម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍន៍និងបង្កើតបទប្បញ្ញត្តិសម្រាប់ភាគីក្នុងកិច្ចសហការបង្កើតយន្តការផ្តល់មូលនិធិសមរម្យ ដើម្បីជួយដល់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តកិច្ចព្រមព្រៀងតាមរយៈការផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ។

ការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ កម្ពុជានឹងទទួលបានផលប្រយោជន៍សំខាន់ៗដូចជា៖

- បង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការលើកកម្ពស់ការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត
- ស្តារទំនុកចិត្តក្នុងការប្រើទង់ជាតិកម្ពុជាដោយនាវាសហគមន៍អន្តរជាតិ
- កែលម្អតម្លាភាពក្នុងអភិបាលកិច្ចជលផល
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិដែលចូលរួមក្នុងការគ្រប់គ្រងកំពង់ផែ
- ជំរុញកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

- សហគមន៍អន្តរជាតិទទួលស្គាល់ឆន្ទៈនយោបាយ ការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត
- កម្ពុជានឹងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាពបន្ថែម ដើម្បីឆ្លើយតបនឹងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ពិសេសអាចឱ្យសហភាពអឺរ៉ុបដកកាតក្រហមចេញពីកម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិដែលរួមមាន ៣ មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់នេះ ដោយក្តីអនុគ្រោះ។

ថ្ងៃ សុក្រ ៥ កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**